# ការសម្ភាសរបស់ពូគឹមឆៃយ៉ា

កៈអ្នកធ្វើការសម្ភាសន៍ឈ្មោះ ហេងសុជីវី  ខៈអ្នកត្រូវគេសម្ភាសន៍ឈ្មោះគឹមឆៃយ៉ា

កៈ ពូជាដំបូង សូមជំរាបសួរពូ!!

ខៈបាទ!

កៈចាស! អរគុណពូ។ ថ្ងៃនេះខ្ញុំមានឳកាសមកសំភាសពូផ្ទាល់ ខ្ញុំបានធ្វើការស្ម័គ្រចិត្តក្នុងគំរោងរបស់សាលា BYU របស់សហរដ្ឋអាមេរិក ហើយគំរោងមួយនេះតំរូវឲ្យនាងខ្ញុំសំភាសន៍ប្រជាជនកម្ពុជា មានវ័យចាប់ពី៣៥ឆ្នាំឡើងអំពីជីវៈប្រវត្តិ បទពិសោធន៍ជីវិត តាំងពីមុនមកដល់ឥឡូវគាត់ឆ្លងកាត់បទពិសោធន៍ជីវិតអីគេខ្លះ ដើម្បីចែកចាយឲ្យកូនចៅជំនាន់ក្រោយបានស្ដាប់នូវសំលេង និងបទពិលោធន៍ប្រវត្តិរបស់ពូ។ ចាសចឹងនៅពេលដែលខ្ញុំមានឳកាសមកសំភាសពូ តើពូអនុញ្ញាតិឲ្យខ្ញុំថតសំលេងរបស់ពូ និងផុសនៅក្នុងវេបសាយរបស់សាលាដើម្បីឲ្យកូនចៅជំនាន់ក្រោយគាត់បានស្ដាប់ដែរឬទេ?

ខៈបាទ! បាន!

កៈ ចាស!អញ្ចឹងអរគុណពូ!ច្រើន។ ចឹងដំបូងនៃការសំភាស ថ្ងៃនេះជាថ្ងៃទីប្រាំបី ខែប្រាំពីរឆ្នាំពីរពាន់ដប់ប្រាំបី(8/7/2018) ហើយការសំភាសន៍ដំបូង ខ្ញុំសូមសួរឈ្មោះរបស់ពូ។ តើពូមានឈ្មោះអីដែរ?

ខៈខ្ញុំបាទមានឈ្មោះថាគឹមឆៃយ៉ា។

កៈ លោកពូចុះឈ្មោះនេះត្រូវជាមួយអត្តសញ្ញាណប័ណ្ណលោកពូទេ?

ខៈឈ្មោះនេះមាននៅក្នុងអត្តសញ្ញាណប័ណ្ណនឹងគឺដូចគ្នា។

កៈទាំងនាមត្រកូលទាំងអស់មែនលោកពូ?

ខៈបាទ!

ក៖ចុះឈ្មោះក្រៅលោកពូមានទេ?

ខ៖ខ្ញុំអត់មានឈ្មោះក្រៅនោះទេមិនមានទេ មិនមានឈ្មោះក្រៅនោះទេ។

ក៖ចុះឈ្មោះនេះអ្នកណាអ្នកដាក់ឲ្យពូដែរ?

ខ៖ឈ្មោះនេះនឹងលោកឪពុករបស់ខ្ញុំនឹងគាត់បានអ្នកដាក់ឲ្យឈ្មោះនឹងអោយដល់ខ្ញុំ។

ក៖គាត់មានបានប្រាប់ពូថាឈ្មោះនឹងមានអត្ថន័យយ៉ាងម៉េចខ្លះដែរឬទេកាលនឹង?

ខ៖និយាយរួមទៅកាលនឹង ដូចជាមានខ្លះៗដែរ ដូចជាតាមគាត់មើលរឿងល្ខោន ចឹងបានគាត់ដាក់ឈ្មោះខ្ញុំចឹង
ហើយបងប្អូនខ្ញុំទាំងអស់មានឈ្មោះតួល្ខោនទាំងអស់មួយរឿងនឹងតែម្តង។

ក៖អូ!!!.... ល្អមែនទែន! ចឹងអត្ថន័យជ្រាលជ្រៅណាស់លោកពូ។ ហើយពូ ពូអ្នកស្រុកណាដែរ?

ខ៖ ខ្ញុំមាន ស្រុកកំណើតនៅខាងខេត្តតាកែវ។

ក៖នៅក្នុងឃុំអីដែលលោកពូ?

ខ៖ ពូនៅក្នុងភូមិ ត្នោតជុំ ឃុំសំបូរ ស្រុកទ្រាំងខេត្តតាកែវ។

ក៖ ចាស !ចុះសព្វថ្ងៃពូមានទីលំនៅ នៅទីណាដែរ?

ខ៖សព្វថ្ងៃនេះពូមានទីលំនៅនឹង..... និយាយទៅអឺ...ស្នាក់នៅភ្នំពេញ នៅកន្លែងធ្វើការតែម្តង។

ក៖ចាស !នៅក្នុងសង្កាត់ ក្នុងខណ្ឌណាដែលពូ?

ខ៖អត់ !អត់!ដឹងច្បាស់ គ្រាន់តែដឹងថាក្នុងសង្កាត់ទឹកល្អក់។

ក៖សង្កាត់ទឹកល្អក់ ចុះលោកពូឥឡូវមានអាយុប៉ុន្មានឆ្នាំដែរហើយ?

ខ៖ខ្ញុំមានអាយុ៣៧ឆ្នាំហើយ។

ក៖លោកពូកើតនៅក្នុងថ្ងៃខែ ឆ្នាំណាដែរ?

ខ៖ខ្ញុំបានកើតនៅថ្ងៃទីប្រាំមួយខែប្រាំឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបមួយ(ថ្ងៃទី៦ខែ៦ឆ្នាំ១៩៨១)។

ក៖ចុះចំណែកឯឆ្នាំចន្ទ្រគតិ សុរិយគតិរបស់ខ្មែរយើងវិញ តើលោកពូកើតឆ្នាំអីដែរ?

ខ៖ដូចជាអត់ចាំទេរឿងមួយនឹងអត់បានចាំនោះទេឆ្នាំខ្មែរនឹង។

ក៖ដូចឆ្នាំសត្វ ឆ្នាំជូត ឆ្នាំឆ្លូវ អីចឹងណាលោកពូ?

ខ៖ អ!!... ឆ្នាំរការ។

ក៖ចាស! លោកពូ!សព្វថ្ងៃមានមុខរបរជាអីដែល?

ខ៖និយាយទៅ ខ្ញុំគឺមានមុនរបរជាសន្តិសុខសាលារៀន។

ក៖ពូធ្វើការងារបានប៉ុន្មានម៉ោងដែរ នៅក្នុងមួយថ្ងៃ?

ខ៖និយាយទៅខ្ញុំបានធ្វើការងារ១នេះនឹងណាអត់មានបានថាកំណត់ម៉ោងផង... កំណត់ទៅតាមគោលដៅដែលយើងនៅចឹងហា។ប្រសិនបើយើងនៅនៅចាំនៅខាងច្រកមុខនឹងចឹងម៉ោងប្រហែលជាម៉ោងប្រាំពីរ ឬក៏ម៉ោង... ...!!ពេលខ្លះមានចាំបាច់យើងនៅដល់ម៉ោងប្រាំបី កន្លះបានយើងអាចសម្រាកបាន។

ក៖ចាសពូ! ចឹងថ្ងៃសៅរ៍អាទិត្យគឺអត់មានសម្រាកដែរ?

ខ៖តាមពិតនិយាយទៅបើយើងប្រចាំការ នៅអាគារអេ(A)គឺគាត់ឲ្យត្រូវយើងឡើងមកមើលប្រចាំ។

ក៖ចុះមួយឆ្នាំមួយខែពូអាចមានថ្ងៃសម្រាកដែរឬទេ?

ខ៖និយាយទៅ ដល់ពេលនៅក្នុងមួយសប្តាហ៍ខ្ញុំសម្រាកមួយតែថ្ងៃ សម្រាក ខ្ញុំសម្រាកថ្ងៃអង្គារ។

ក៖ចុះលោកពូបានប្រាក់ខែប៉ុន្មានដែរ?

ខ៖ប្រាក់ខែរបស់ខ្ញុំនឹងវាបានតែ....បើសិនជា និយាយទៅសាលាគាត់ឲ្យ៥០$ហើយប្រាក់ខែគោលរបស់ខ្ញុំនឹងគឺ១២០$ ហើយខាងរោងកង់គាត់ឲ្យ១៥$ ទៀតចឹងហា មានតែប៉ុណ្ណឹងទេ។

ក៖ហើយពូមានការងារក្រៅដែរទេលោកពូ?

ខ៖អត់មានទេ!!... ធ្វើតែការងារនឹងនៅក្នុងមួយកន្លែងនឹងទេអត់មានការងារក្រៅអីមួយទៀតនោះទេ។

ក៖ហើយលោកពូកាលពីមុនមកលោកពូធ្លាប់ធ្វើការអីខ្លះដែរ?

ខ៖ពីមុនធ្លាប់ធ្វើដែរ ដូចធ្វើសំណង់ក៏ធ្លាប់ ធ្លាប់ជាជ័រក៏ធ្លាប់ ហើយនិយាយទៅធ្វើស្រែក៏ធ្លាប់។

ក៖ចឹងការងារច្រើនដែរ ពូធ្លាប់មានបទពិសោធន៍ធ្វើពូ ការងារទាំងអស់នឹងពូគិតថាពូស្រលាញ់ការងារមួយណាជាងគេទៅ?

ខ៖និយាយទៅកាលពីមុននឹងខ្ញុំបានអី.......ខ្ញុំបានអី...... ខ្ញុំស្រលាញ់ការងារសន្តិសុខនឹងដែរនឹងវាស្រួលជាងការដែលខ្ញុំធ្លាប់បានធ្វើកន្លងមក។

ក៖ហេតុអីបានជាចឹងដែរទៅលោកពូ?

ខ៖និយាយទៅកាលនឹងគឺថាយើងមិនវាបានប្រើកំលាំងខ្លាំង ហើយមួយទៀតយើងបាននៅជាមួយអ្នកចេះដឹងច្រើនចឹងហា... នៅកន្លែងអប់រំ។

ក៖ចុះលោកពូមានគំណិតថាចង់ផ្លាស់ប្តូរឬរកការងារអីបន្ថែមដើម្បីរកប្រាក់ចំណូលបន្ថែមទេ?

ខ៖ខ្ញុំនឹងវាចង់ដែរនឹង ចង់ដែរ ប៉ុន្តែកន្លែងនេះយើងអត់អាចទៅធ្វើអីផ្សេងបានចឹងហា... បើអាចឆ្លៀតបានដូចជាថ្ងៃយើងសម្រាកចឹងហា ពេលខ្លះក៏ឆ្លៀតរត់ម៉ូតូឌុបដែរ។ គ្រូៗគាត់ឲ្យដឹកអីចឹងហា ប៉ុន្តែទៅបានតែពេលយើងនៅបីអ្នកអីទេ យើងអាចទៅម្នាក់ ហើយប្រសិនបើគេអត់នៅយើងអត់អាចទៅបាន....

ក៖ចាស! ចុះមុនដំបូងនៃការងារ ពូហេតុអីបានជាពូបានមកធ្វើការងារនៅនឹង?

ខ៖និយាយទៅកន្លងមកខ្ញុំធ្លាប់ធ្វើជាសន្តិសុខក្រុមហ៊ុន គឺគេយកមកដាក់នៅសាលានឹង។ ដល់ពេលគេមើលការងារខ្ញុំ ថាខ្ញុំធ្វើការគ្រាន់បើជាងគេក្នុងចំនោមបុគ្គលិកក្រុមហ៊ុនទាំងអស់នឹង គេឲ្យចូលមកក្នុងនឹង ដល់ពេលធ្វើទៅប្រពន្ធគាត់ឆ្លងទន្លេ យើងត្រូវទៅនៅជិតប្រពន្ធ ចឹងខ្ញុំឈប់ពីក្រុមហ៊ុននឹងមួយរយះ។ ដល់ពេលខ្ញុំទៅជាជំរជាមួយគ្រួសារខ្ញុំ ជួយមើលគាត់ មើលអាតូចនឹងផង រាងធំតិច ខាងសាលាគេទាក់ទងទៅខ្ញុំ ចង់គេខ្វះកំលាំងហើយគេគិតថាខ្ញុំធ្លាប់ធ្វើការនៅនឹង កន្លងពីមុនខ្ញុំក៏ធ្លាប់សុំគាត់ចូលសាលាដែរ ប៉ុន្តែអត់មានអ្នកធានាញុំចឹងហា ប៉ុន្តែដល់ឥឡូវគេតេថាមិនបាច់មានអ្នកធានាឲ្យមកមក ចឹងបានខ្ញុំមកនឹងវិញ។

ក៖ចាស! ការងាររាល់ថ្ងៃដែលពូធ្វើនឹងអាចនឹងចិញ្ចឹមគ្រួសារពូ ទុកឲ្យកូនរបស់ពូបានដែរឬទេ?

ខ៖និយាយទៅ ប្រាក់ខែប៉ុន្នេះគ្រាន់តែខ្ញុំចាយតែខ្លួនខ្ញុំនឹងវាល្មមសមរម្យ ហើយបើថាឲ្យយកទៅចិញ្ចឹមកូន យកទៅជួយកូនរៀងពិបាកតិច ប៉ុន្តែធ្វើម៉េចបើយើងមិនដឹងទៅធ្វើអីហើយ មានតែតាមនឹង។

ក៖ចុះអ៊ឺ!!.... ភរិយាលោកពូធ្វើការអីដែល?

ខ៖ប្រពន្ធខ្ញុំគាត់កឹបសំបុត្រកង់ម៉ូតូ។

ក៖នៅសាលាដែរ?

ខ៖បាទ!គាត់គឺជាអ្នកដែលកឹមសំបុត្រម៉ូតូនៅឯក្នុងសាលារៀននឹងដែរនឹង។

ក៖ហើយគាត់រៀបការជាមួយលោកពូប៉ុន្មានឆ្នាំហើយ?

ខ៖និយាយទៅខ្ញុំបានរៀបការនឹងតាំងពីនៅក្នុងឆ្នាំ តាំងពី២០០៤មកម្ល៉េះ!!! ឥឡូវវាជាងដប់ឆ្នាំហើយ។

ក៖ចាស!ចឹង ដប់បួនឆ្នាំ(១៤ឆ្នាំ)ហើយ!!

ខ៖បាទ!

កៈហើយគាត់ឈ្មោះអីគេដែលលោកពូ?

ខៈគាត់មានឈ្មោះថា យ៉ុន ផេង។

កៈហើយលោកពូមានកូនប្រុសស្រី អឺ......កូនប៉ុន្មានអ្នកដែរ?

ខៈខ្ញុំមានកូនបីនាក់។

កៈស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ខៈខ្ញុំមានកូនស្រីចំនួនបានមួយនាក់ហើយនឹងកូនប្រុសបានចំនួនពីរនាក់ដែរ។

កៈគាត់ឈ្មោះអីខ្លះដែរទៅពូ?

ខៈគាត់មានឈ្មោះថាអឺ!!!...... ផាតវ៉ាយុ កូនទី១ កូនទី២ឈ្មោះអឺផាតណារី កូនទី៣ឈ្មោះផាតជំនោរ។

កៈចាស! ចុះកូនម្នាក់ៗគាត់មានអាយុប៉ុន្មានឆ្នាំហើយពូ? គាត់រៀបការខ្លះនៅ?

ខៈនិយាយទៅកូនខ្ញុំនៅមិនទាន់ការទេ។ អាបងទើបមានអាយុដប់ប្រាំឆ្នាំ អត់ទាន់បានដប់ប្រាំឆ្នាំ ទេ !!ហើយកូនស្រីអាយុដប់បីឆ្នាំ ហើយអាតូចជាងគេនឹងបីឆ្នាំជាង បីឆ្នាំ ដប់ខែ។

កៈចាស !ចុះកូនពូកំពុងសិក្សា គាត់រៀននៅណាខ្លះដែរ?

កៈចុះឪពុកម្ដាយរបស់ពូត្រូវជាយាយតារបស់ប្អូន គាត់មានឈ្មោះអីដែរ?

ខៈគាត់បានរៀននឹងកាលនឹងនៅក្នុងឯ....នៅខេត្តតាកែវ នៅជាមួយយាយតា រៀនអឺអាបងរៀនទីប្រាំបី អាទី២រៀនទីប្រាំពីរហើយអាតូចនឹងអត់ទាន់រៀនទេ។

ខៈឪពុកម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ប្រាក់សុផាត ឪពុកខ្ញុំ។ ចំណែកឯខាងម្ដាយគាត់មានឈ្មោះថា ជៀងគីមហឿន។

កៈគាត់អ្នកស្រុកតាកែវទាំងពីរនាក់ក៏យ៉ាងម៉េច?

ខៈបាទ!

កៈហើយគាត់មានប្រាប់ពូថាកាលពីជំនាន់ប៉ុលពត គាត់ជួបការលំបាកអីខ្លះ ធ្លាប់ត្អូញប្រាប់ពូទេ?

ខៈគាត់ធ្លាប់ប្រាប់ដែរ គាត់ នឹងពីក្មេងគាត់គ្មានខោអាវស្លៀកពាក់ដូចយើងចឹងទេ។ គាត់មានតែខោមួយអាវមួយ (សំលេងរំខានពីខាងក្រៅមកដែលពេលមានម៉ូតូនឹងមានឡានកំពង់តែជិះកាត់នឹងហើយមាន សំលេងបើកបរនៅតាមផ្លូវលឺស្ងរ ត្រែងៗៗៗ វឺសៗៗៗ) ទៅរៀនក៏មិនបាន ហូបបាយ បាយគ្មានចំនី គ្មានលុយទៅរៀនអីអត់ទេ ហូបតែបាយកកពេលព្រឹកចឹងទៅ។ ហើយបើនិយាយពីពេលគាត់នៅជំនាន់ប៉ុលពតវិញ ពួកគាត់គេប្រើឲ្យធ្វើការហួសកំលាំង មានពេលខ្លះដែលគាត់ឃ្លានខ្លាំងពេក គាត់បូតគ្រាប់ស្រូវ ដែលស្រូវទុំតាមស្រែ បូតអានឹងយកមកហូបទៅ។

កៈចាសបង! ហើយកាលនឹងគាត់មានប្រាប់ពូថាធ្វើម៉េចចិញ្ចឹមពូមកដល់ធំចឹង? គាត់មានបានប្រាប់ពូទេ?

ខៈនិយាយទៅ!កាលដែលគាត់ចិញ្ចឹមខ្ញុំនឹងកាលនឹងបាន ផុតប៉ុលពតហើយ ដូចជាមិនពិបាកដូចដែលនៅជំនាន់ប៉ុលពតទេ ព្រោះពេលនោះធ្វើស្រែធ្វើស្រូវអីយើងបានហូបពេញលេញ គ្រាន់តែថាមិនមែនជាកូនអ្នកមានអីទេ គ្រាន់តែថាអាចម៉ារស់បាន ហើយគ្រាន់តែថាគាត់មិនសូវជាចាយលុយអី គាត់សន្សំសំចៃច្រើនណាស់ បើខ្ញុំខុសពីគាត់រៀងចាយលុយធូរជាងគាត់តិច។

កៈចាសពូ!។

ខៈបើគាត់ គាត់បានធ្វើការសន្សំទៅគាត់មានផ្ទះមានអី។ ខ្ញុំរាល់ថ្ងៃខ្ញុំអត់មានផ្ទះខ្លួនឯងទេ ជួលផ្ទះគេនៅនោះទេសព្វថ្ងៃនឹងនោះខ្ញុំបានជួលផ្ទះគេទេ។

កៈនៅភ្នំពេញ?

ខៈបាទ!!

កៈមួយខែពូចំនាយប្រាក់អស់ប៉ុន្មានដែរ?

ខះនៅក្នុងមួយខែនឹងខ្ញុំអាចនឹងធ្វើការចំនាយទៅអស់ប្រហែលជាបានអស់៨០$។

កះទាំងផ្ទះទឹកភ្លើងអីមែនលោកពូ?

ខះអានឹងយើងបានគិតទាំងទឹកភ្លើងគាត់ថែម១ម៉ឺន(១០០០០រៀល)ទៀត និយាយទៅប្រហែល៨២$។

កះនៅម្ហូបនៅថ្លៃកូនចាយអីទៀត ប្រហែលជាអស់ប៉ុន្មានដែរទៅលោកពូ?

ខះត្រូវការផ្ញើរលុយឲ្យកូនចាយនៅខេត្តអីទៀត។ និយាយទៅខ្ញុំមានបញ្ហាខាងលុយនឹងខ្លាំង និយាយទៅពេលខ្លះយើងត្រូវការ វាចៃដន្យ លុយមានតែម៉ាផ្គត់ផ្គង់ថាឲ្យកូនរៀនគ្រប់ចាយគ្រប់អីចឹងហា! តែដល់យើងឈឺយើងពិបាកត្រូវការខ្ចីលុយគេ ចឹងវាមានបញ្ហានឹងដែរ ប៉ុន្តែបើយើងអត់ឈឺអត់អីទេ។

កះចុះពូរាល់ថ្ងៃមានឈឺអីទេពូ?

ខះនិយាយទៅខ្ញុំដូចជាមានឈឺបញ្ហាពោះវៀនម្តងម្កាលដែរនឹង។

កះពោះវៀនតូច ពោះវៀន?

ខះខ្ញុំវាអត់សូវបានជាច្បាស់ អត់ច្បាស់ដែរ ខ្ញុំ វាដឹងថាវាបានឈឺពោះវៀន។

កះពូធ្លាប់ទៅពេទ្យពិនិត្យមើលដែរឬទេ?

ខះខ្ញុំបានធ្លាប់ទៅជួសមើលឈាមជួសអីមើលដែរ! តែវាឲ្យលេបថ្នាំឲ្យតមខ្ញុំហូបស្រាហូបអីដែលនឹងណា។

កះអ!..... ចាស! ស្រាវាប៉ះពាល់ច្រើនណាស់។

ខះបាទ! ដឹងដែរតែពេលខ្លះមនុស្សយើងដូចមានបញ្ហា (សំលេងរំខានពីខាងក្រៅនៅលើផ្លូវមានសំលេងបើកបរឡាននឹងមានម៉ូតូជិះនៅតាមផ្លូវជិតការសំភាសន៏ដែរតែនៅក្នុងរបងរបស់ខាងសាលារៀន គ្រែង១១១ រឺត១១១!!) និយាយទៅវាអាចឲ្យយើងដេកលក់។

កៈចឹងយើង!           ដូចជាពេលពូឈឺចឹងខាងសាលាគេមានជួយអីឲ្យពូដូចខាងធានារ៉ាប់រងខាងសុខភាពឲ្យពូទៅពិនិត្យមើល ពិនិត្យអីអត់?

ខៈដូចជាអត់មានទេ។

កៈចុះខាងក្រុមហ៊ុនដែលឲ្យពូមកធ្វើធានារ៉ាប់រងនឹងទេគេអត់មានទេ?

ខៈក្រុមហ៊ុននៅក្នុងសម័យកាល
ពីមុននឹងនៅក្នុងជំនាន់ដែលពូបានធ្វើការងារមួយនឹងគឺលោកពូអត់បានគេអត់មានអីចឹងទេកាលនឹង គេអត់នឹងមានការធានារ៉ាប់រងសំរាប់ពេលយើងនឹងបានឈឺនឹងក៏អត់មានដែរ។

កៈចាស !ហើយពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ខៈខ្ញុំមានបងប្អូនប្រាំពីរនាក់។

កៈគាត់ឈ្មោះអីខ្លះទៅពូ?

ខៈឈ្មោះគឹមស៊ីថា កូនទី២។ ហើយគឹមចំណាប់ មួយទៀត ។គឹមសូត្រសារឿន កូនស្រីគឹមសុភាព។ ប្រុសហើយគឹម បញ្ញា ប្រុសដែរ។ ហើយគឹមសម្គស្ស ពៅចុងក្រោយ។ ហើយខ្ញុំកូនបងគេ កូនទីមួយ

កៈចាស!ចឹងពូកូនបង ត្រូវជាកូនច្បងនៃគ្រួសារ?

ខៈបាទ!!

កៈហើយបងប្អូនរបស់ពូរៀបការរៀបអាពាពិពាហ៍អីអស់ហើយនៅពូ ទាំងប្រាំពីរនាក់នឹង?

ខៈនៅសល់ពីរនាក់ទៀត                    នៅសល់កូនទីប្រាំមួយនិងកូនទីប្រាំពីរកូនពៅមួយនិងបន្ទាប់ពៅមួយ។

កៈចាសពូ! ហើយចឹង ដូចជាបងប្អូនរបស់ពូគាត់មានមុខរបរអីខ្លះដែរ គាត់រៀបការហើយ?

ខៈនិយាយទៅកូនទីមួយនឹង អឺបន្ទាប់ខ្ញុំនឹងគេ គេធ្វើការរោងចក្រ ធ្វើជាមួយប្រពន្ធគេ។ ហើយអឺមួយទៀតគេ ប្អូនខ្ញុំគេនៅខាងធនាគារ គេរៀនបានខ្ពស់ជាង គេប្រាក់ខែគួរសមដែរ។

ក៖ចាស!

ខ៖កូនមួយទៀតកូនទី៤នឹង គាត់នៅផ្ទះទេពីមុនគាត់ធ្វើការរោងចក្រដែរ ប៉ុន្តែពេលមានកូនទៅអត់បានទៅធ្វើការកើតហា ព្រោះអីជាប់មើលកូន។ ហើយអឺមួយទៀតគេធ្វើការខាងប្រេងសាំង ក៏គេរៀនបានខ្ពស់ដែរ គេបានរៀនចប់បរិញ្ញាប័ត្រ។ ហើយមួយទៀតគេរៀនបាន គេចប់បរិញ្ញាប័ត្រមួយទៀតហើយ គឺមបញ្ញានឹង។ ហើយប្អូនពៅខ្ញុំនឹងគេកំពុងបន្តបរិញ្ញាប័ត្រ ទើបចូលឆ្នាំទីមួយ។

ក៖ចាស !បងប្អូនរបស់លោកពូស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរ?

ខ៖ខ្ញុំមានបងប្អូននឹងមានស្រីចំនួនបានពីរនាក់ហើយប្រុសមានចំនួនបាន ប្រុស៥ នាក់នឹងអ្នករៀនបានខ្ពស់ៗនឹងនិយាយទៅ៣នាក់ដែរនៅក្នុងគ្រួសាររបស់ខ្ញុំនឹង។

ក៖បានបីនាក់ចឹង?

ខ៖ខ្ញុំមានបងប្អូនឹងគាត់បានរៀនខ្ពស់ៗនឹងមើលវាបានប្រហែលជាបាន៣នាក់ ៤នាក់ដែរអីដែឬនឹង។

ក៖ចឹងបងប្អូនលោកពូពេលដែលមានបុណ្យទាន ក៏ដូចជាចូលឆ្នាំអីធំៗ ទៅជុំគ្នានៅផ្ទះនៅខេត្តតាកែវនឹង?

ខ៖បាទ! ជួបជុំគ្នា !ពេលណាមួលៗ ពេលណាគេរវល់ជួបជុំគ្រួសារគេ ក៏អត់បានទៅ។ ហើយដូចខ្ញុំ មួយឆ្នាំទៅខាងម៉ែខ្ញុំមួយឆ្នាំទៅខាងប្រពន្ធខ្ញុំ ព្រោះគេក៏ចង់ជួបជុំបងប្អូនគេដែរ។ ហើយបើមួយឆ្នាំទៅទាំងពីរកន្លែងក៏យើងត្រូវការចំណាយច្រើនដែរ យើងអាចផ្ញើរតែលុយទៅឲ្យគាត់បាន។

ក៖ចុះទាក់ទងជាមួយនឹងថាក្រុមគ្រួសាររបស់ខាងលោកពូទាំងពីរ តែលោកពូត្រូវឆ្លៀតពេលទៅខាងប្រពន្ធផងខាងលោកពូផងចឹងធ្វើម៉េចដើម្បីឲ្យលោកពូនៅកណ្តាលកុំឲ្យលំអៀងស្រលាញ់ខាងសាច់ឯងជាង ខាងសាច់ប្រពន្ធអញ្ចឹងតើលោកពូមានវិធីសាស្រ្តយ៉ាងណាដែរ?

ខ៖អ......!! ខ្ញុំបាននិយាយពិភាក្សាជាមួយប្រពន្ធខ្ញុំ។ ប្រសិនបើជាឧទាហរណ៍ថាខ្ញុំចង់ទៅតាកែវ ត្រូវសួរគាត់ដែរ បើសិនគាត់ថាទេបងប្អូនមកពីណាពីណីគាត់ចង់មកជួបជុំគ្នាចឹង យើងអាចផ្លាស់ប្តូរទៅខាងនោះបាន។ ខ្ញុំទ្រាំជាមួយគាត់ច្រើន ពេលខ្លះគាត់អត់សួរស្តាប់ខ្ញុំ គាត់ធ្វើតាមចិត្តគាត់ ព្រោះកាលណាដែលយើងនាំគាត់ទៅលេងផ្ទះគ្រួសារយើង គេអត់សប្បាយ គេអត់ចង់ទៅក៏គេអត់សប្បាយដែរ ខ្ញុំក៏អត់សប្បាយចិត្ត ចឹងសំខាន់ទៅលើចំនុចនឹង។ បើសំរាប់ខ្ញុំមួយខ្ញុំមិនចង់ទៅក៏ខ្ញុំសម្របខ្លួនឲ្យសប្បាយដែរ ព្រោះខ្ញុំមិនមែនស្រលាញ់តែប្រពន្ធខ្ញុំទេ ខ្ញុំស្រលាញ់ទាំងគ្រួសារគេដែរ។

ក៖ចាស! ត្រូវហើយលោកពូ។ ចុះតាមរយះជីវិតបទពិសោធន៍របស់លោកពូតាំងពីមុនដល់ឥឡូវមានច្រើនមែនទែនលោកពូ ចឹងតើលោកពូពីតូចមក ពូធ្លាប់មានក្តីស្រម៉ៃថាចង់ធ្វើអីទេ?

ខ៖និយាយទៅកាលដែលខ្ញុំនៅតូច ខ្ញុំចង់រៀន ខ្ញុំអត់ចង់ធ្វើស្រែទេ ព្រោះខ្ញុំនៅពីតូចខ្ញុំរៀនផងធ្វើស្រែផងអីផង គឺថាហត់នឿយណាស់អ្នកធ្វើស្រែចំការ ខ្ញុំមិនដែលគិតថាខ្ញុំចង់ធ្វើស្រែទេ។ កាលនោះខ្ញុំមិនបានគិតថារៀនចប់ខ្ញុំបានធ្វើអីទេ គ្រាន់តែគិតថាចង់រៀនឲ្យបានខ្ពស់ គិតចឹងទេ អត់បានគិតទេ ព្រោះអត់មានអ្នកណាបង្ហាញគោលដៅយើង។ កាលនោះគ្រាន់តែចង់រៀនឲ្យបានខ្ពស់ ប៉ុន្តែខ្ញុំ និយាយទៅដោយសារខ្ញុំកូនបងគេ គាត់ប្រើឲ្យយើងធ្វើការ ថ្ងៃខ្លះអត់បានទៅរៀនចឹងគាត់ឲ្យខ្ញុំឈប់មួយថ្ងៃពីរថ្ងៃចឹងទៅ ចឹងយើងរៀនអត់ទាន់គេទេ។ មានពេលខ្លះកង់អត់ទាន់ អត់ដល់ម៉ោងចឹងណា កង់ធ្លាក់ច្រវ៉ាក់ផងអីផង ខោអាវតែមួយកំផ្លេទេ ទៅរៀនឆ្ងាយពីផ្ទះ ដល់ពេលត្រលប់មកវិញយើងត្រូវមកហូបបាយផ្ទះវិញ មកវិញជួនកាលភ្លៀងសើមខោអាវអស់ មកដល់ផ្ទះរលស់ខោអាវដាក់ហាលអីចឹងហា ហើយនៅសើមតិចៗជិះមករៀនវិញមកស្ងួត មកដល់សាលាស្ងួតបាត់។ ខ្ញុំអត់មានខោអាវផ្លាស់ប្តូរអីដូចប្អូនៗឥឡូវនេះទេ។

ក៖ពេលនោះពូរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖កាលនៅពេលនោះនឹងខ្ញុំចូលរៀនបានត្រឹមថ្នាក់ទីប្រាំបី និយាយកាលនឹងខ្ញុំនឹងគាត់បានអោយទៅគាត់ឲ្យខ្ញុំអឺ...... ខ្ញុំរៀនដល់នឹងហើយគាត់ឲ្យខ្ញុំឈប់ទៅវិញទៅកាលនឹងនោះរៀនអនោះត់បានរៀននឹងគេនោះផងកាលនឹង។ ខ្ញុំរៀនអត់ទាន់គេ យើងរៀនដល់ថ្នាក់នឹងហើយបើសិនជាយើងនៅខ្ញុំគិតខ្ញុំសំរេចចិត្តទៅមុខអត់រួច។

ក៖នៅខ្វះមួយឆ្នាំទៀតទី៩ប្រលងហើយនឹងលោកពូ?

ខ៖បាទ! បើសិនជាពេលនឹងម៉ែរបស់ខ្ញុំគាត់ជំរុញឲ្យខ្ញុំបានរៀន ប៉ុន្តែគាត់ចង់ឲ្យខ្ញុំរៀនប៉ុន្តែគាត់អត់មានជំរុញអ្នករៀនឲ្យចង់រៀនចឹងហា!! ខ្ញុំខ្វះ គេរៀនគួរផង គេរៀនអីផង ប៉ុន្តែខ្ញុំអត់តូចចិត្តទេ សំខាន់ឲ្យតែខ្ញុំបានទៅរៀនជាប់។ ពេលគាត់ឲ្យឈប់ចឹងខ្ញុំអស់អារម្មណ៍រៀនដែរ។ ខ្ញុំទៅជួយស្ទូងគាត់រហូតដល់មួយខែ ឈប់រៀនមកវិញប្រលងផងអីផង សួរមិត្តភក្តិផងអីផង ខ្ញុំរៀនបាន៤ ទៅ៥ថ្ងៃ ប្រលងគេមិនទាន់អស់ផង គាត់ឲ្យឈប់ទៀត ឈប់បណ្តោយទៅមិនបាច់ប្រលងទេ។ បានប្អូនៗក្រោយគេបានរៀនបានខ្ពស់ ប្រសិនបើខ្ញុំនៅបន្តរៀន គឺថាប្អូនៗប្រហែលជាមានអ្នកខ្លះរបូត។

ក៖ចឹងកាលនឹងលោកពូរៀននៅសាលាណាដែរកាលនឹង?

ខ៖ខ្ញុំបានរៀនខាងឯខាងនៅសាលារៀនអនុវិទ្យាល័យព្រៃកទប់។

ក៖កាលនឹងពូបានរៀននៅក្នុងអនុវិទ្យាល័យអីគេលោកពូ?

ខ៖កាលនឹងខ្ញុំបានរៀននៅក្នុងអនុវិទ្យាល័យព្រៃកទប់។

ក៖នៅខេត្តតាកែវណា លោកពូ!

ខ៖បាទ!

ក៖ពូកាលនោះកាលរៀន ហើយការសិក្សានឹងវាដូចតែសម័យយើងដែរឬទេហាលោកពូ អត់មានផ្លាស់ប្តូរអីទេហា? គឺមានដូចតែយើង មានថ្នាក់ទីមួយ រហូតថ្នាក់ទីប្រាំមួយចឹង

បឋមសិក្សា? ថ្នាក់ទីប្រាំពីរដល់ថ្នាក់ទីប្រាំបួនចឹងអនុវិទ្យាល័យ? ដល់ពេលទីដប់ដល់ទីដប់ពីរចឹង វិទ្យាល័យ?

ខៈកាលជំនាន់មុននោះ ចាំមើលខ្ញុំរៀន កាលនោះខ្ញុំប្រលងទីប្រាំ ប្រលងទីប្រាំចូលទីប្រាំមួយ ដល់ខ្ញុំចេញពីទីប្រាំមួយត្រូវឡើងទីប្រាំពីរ គេទៅកែទៅដាក់ទីប្រាំបីវិញ។ ចឹងខ្ញុំត្រូវចូលទីប្រាំបី តាមពិតខ្ញុំត្រូវចូលទីប្រាំមួយឡើងមកទីប្រាំពីរ ដល់ទៅផ្លាស់ប្ដូរដំឡើងមួយថ្នាក់ទៀតហា។ កាលនឹងបឋមយើងត្រូវឡើងមួយថ្នាក់ទៀតទីប្រាំមួយមួយថ្នាក់ទៀត ចឹងខ្ញុំទៅជាទីប្រាំបីវិញ។

កៈលើកកំរិតមួយថ្នាក់?

ខៈបាទលើក។ ប៉ុន្តែមិនមែនទេមានតែចំនួនទេ តែមើលមុខវិជ្ជាដូចទីប្រាំពីរចឹង។

កៈចឹងសាលាបឋមសិក្សានិងអនុវិទ្យាល័យនៅជាមួយគ្នាឬពូ?

ខៈអឺ......!!!និយាយទៅកាលនឹងខ្ញុំបានទៅរៀននៅ សាលានឹងមានទាំងសាលាបឋមដែរ ប៉ុន្តែរៀនបឋមរៀននៅក្នុងភូមិដល់អនុវិទ្យាល័យខ្ញុំត្រូវឡើងមកឆ្ងាយ ចូលប្រហែលជា១០គីឡូម៉ែត្រ។

កៈហើយពូបានចេះប៉ុន្មានភាសាដែរពូ?

ខៈនិយាយទៅកាលជំនាន់ខ្ញុំបានរៀនត្រឹមតែភាសាបារាំង។ ភាសាបារាំងដូចជាចាប់មិនសូវបានទេកាលនឹងនោះ ដូចជាអត់មានអារម្មណ៍ចង់រៀនផង។ ចង់រៀនភាសាអង់គ្លេស ដល់ឥឡូវនឹងភាសាអង់គ្លេសក៏អត់ចេះអីទេឥឡូវនឹង ព្រោះអីរៀនពីគេមកចេះបានមួយម៉ាត់ៗ

កៈចឹងកាលនឹងលោកពូបានចេះអាចនិយាយអាចសរសេរអីបានអត់ពូ?

ខៈអត់! និយាយទៅ! គ្រាន់តែថាពាក្យណាដែលយើងធ្លាប់ឃើញរាល់ថ្ងៃយើងអាចសរសេរបានណា! ពាក្យណាដែលមិនដែល ពាក្យដែលអត់ដឹង គឺអត់អាច។ គ្រាន់តែថាពេលខ្លះនិយាយខ្លះៗពេលមានបរទេសមកសួរអីចឹងហា និយាយបានតិចតួច មិនយកជាការអីបានទេ។

ក៖ពូតាំងពីតូចរហូតមកដល់ឥឡូវនឹងពូមានអ្វីដែលជាការចង់ចាំដូចជាអ្វីដែលធ្វើឲ្យពូពិបាកចិត្ត រាល់ពេលដែលពូនឹកឃើញហើយធ្វើឲ្យពូពិបាកចិត្តដល់ឥឡូវនឹង ដែលអត់អាចធ្វើឲ្យពូបំភ្លេចសោះឡើយ ពូមានដែរឬទេ?

ខ៖ដូចជា គ្រាន់តែគិតថាវាពិបាកចិត្តវាមានតិចតួចដែរ ប៉ុន្តែមិនយកចិត្តទុកដាក់។ ប៉ុន្តែអ្វីដែលខ្ញុំនៅតែគិតនៅតែតូចចិត្តត្រង់ថា សោកស្តាយដែលខ្ញុំមិនបានរៀនបានខ្ពស់ ហើយបានទាប បានតិចចឹងហើយ បានជាខ្ញុំរកប្រាក់ចំនូលអត់បាន។ ដល់អញ្ចឹងបានខ្ញុំសុខចិត្ត ទោះបីជាខ្ញុំខ្វះខាតយ៉ាងណាក៏ដោយ ក៏ខ្ញុំគិតឲ្យកូនខ្ញុំវារៀនបានច្រើនបានខ្ពស់ សុខចិត្តអត់មាន ខ្ញុំអត់សន្សំលុយទុកទិញផ្ទះទិញដីអីទេ សុខចិត្តទុកចំនាយឲ្យកូនរៀនបានខ្ពស់ ថ្ងៃក្រោយគេនឹងធូរជាងខ្ញុំ គេរកលុយទិញខ្លួនគេបាន តែដូចខ្ញុំរកគ្រាន់តែទប់ៗ ឲ្យតែបានកូនរៀននឹងបានហើយ។

ក៖ចឹងកាលនឹងមានតែមួយនឹងទេហាពូដែលធ្វើឲ្យពូពិបាកចិត្ត គិតច្រើន?

ខ៖បាទ!!អ្វីដែលបានធ្វើអោយខ្ញុំនឹងបានគិតច្រើនជាងគេនឹង គឺមានតែ១នឹងប៉ុណ្ណឹងនោះទេ។

ក៖ចុះសំរាប់បទពិសោធន៍ល្អៗក្នុងជីវិតរបស់ពូវិញ។
តើពូមានបទពិសោធន៍ល្អអីគេខ្លះដែលពូចង់ចាំក្នុងជីវិតរបស់ពូ?

ខ៖និយាយពេលនឹងទៅដូចជាមិនមានអីជាធំដុំទេនោះទេអត់សូវមានអីនោះទេរឿងនឹងនោះ។

ក៖ពេលដែលពូនឹកឃើញហើយធ្វើឲ្យពូសប្បាយចឹងហា បទពិសោធន៍បែបណា?

ខ៖សប្បាយខ្លាំងបំផុតនៅពេលដែលកូនស្រីគាត់រៀនបានខ្ពស់។ គាត់រៀនបានលេខតិច សប្បាយចិត្ត។ ចឹងថ្ងៃមុនខ្ញុំធ្វើខួបកំនើតឲ្យកូនខ្ញុំដែរ លើកទឹកចិត្តគាត់ ប្រាប់គាត់ថាកូនឯងរៀនឲ្យបានយកលេខមួយមក និយាយថាចាំប៉ានឹងព្យាយាម ប៉ុន្តែបានតែលេខពីរទេប៉ាធ្វើឲ្យខ្ញុំអត់ចឹងហា បើបានលេខពីរធ្វើឲ្យអត់? ខ្ញុំថាអូខេបានកូន ប៉ុន្តែលេខពីរតិចហាបើបានលេខមួយធ្វើឲ្យរៀងធំតិច។ ចឹងថ្ងៃមុនខ្ញុំធ្វើឲ្យគាត់ ថ្ងៃខួបកំនើតគាត់ថ្ងៃទីពីរខែប្រាំមួយឆ្នាំពីរពាន់ប្រាំមួយ ខួបកំនើតគាត់។

ក៖ចឹងកាលនឹងកូនទីប៉ុន្មានដែលពូ? គាត់ឈ្មោះអីដែល?

ខ៖កូនរបស់ខ្ញុំនឹងទីពីរឈ្មោះផាត ណារី។

ក៖គាត់រៀនថ្នាក់ទីប៉ុន្មានដែរ?

ខ៖ខ្ញុំមានកូនរបស់ខ្ញុំនឹងគាត់បានរៀននៅក្នុងទី៧ ខ្ញុំឲ្យតែពេលនឹកឃើញកូនស្រីខ្ញុំ ខ្ញុំមានអារម្មណ៍ថារៀងសប្បាយចិត្ត។ ហើយបើអាបងរាងពិបាកតិច តែទោះបីជាយ៉ាងណាក៏ខ្ញុំនៅព្យាយាមឲ្យវាធ្វើម៉េចឲ្យវារៀនអត់ឲ្យវាបោះបង់ការសិក្សាទេ ទោះបីជាវារៀនមិនចូលឬក៏វាខ្ជិលយ៉ាងណាក៏ដោយ ខ្ញុំរុញយ៉ាងម៉េចឲ្យវាបានរៀន។ ធម្មតាអ្នកអត់បានរៀននឹង ពេលខ្លះអ្នកអត់រៀនចេះតែមួរម៉ៅម្ដងម្កាលដែរចឹងហា គិតអីគិតឆេវឆាវ យើងនិយាយស្ដីអត់ចេះគិតទុកមុនទេ។

ក៖ចាសពូ !ចឹងអរគុណពូ។ ចុះពូមានពាក្យអីចុងក្រោយដើម្បីនិយាយផ្ដែរផ្ដាំដល់កូនចៅជំនាន់ក្រោយជាពិសេស អ្នកដែលគេបានស្ដាប់សំលេងលោកពូនិងកូនចៅរបស់លោកពូផ្ទាល់?

ខ៖និយាយទៅខ្ញុំចង់ ផ្ដាំទៅក្មេងៗជំនាន់ក្រោយបូករួមទាំងកូនខ្ញុំដែរ កុំឲ្យចំនាយពេលវេលាអត់ប្រយោជន៍ ហើយខំប្រឹងសិក្សារៀនសូត្រ។ ទាន់មានឪកាសសិក្សានឹងហើយដែលធ្វើឲ្យ ថ្ងៃក្រោយទៅរកប្រាក់ចំនូលដោយខ្លួនឯង ធ្វើឲ្យយើងមានប្រាក់ខែច្រើន ហើយទៅណាមកណាក៏គេរាប់អានស្រលាញ់យើងដែរ បាទខ្ញុំមានតែប៉ុណ្ណឹងទេ

ក៖ចាស! អរគុណពូ!សម្រាប់ថ្ងៃនឹងដែលចំនាយពេលវេលា។ ហើយខ្ញុំបានចូលរួមសម្ភាសនៅក្នុងឪកាសនឹងសង្ឃឹមថាបំណាងប្រាថ្នារបស់ពូនឹងបានសម្រេច ហើយជូនពរឆ្នាំថ្មី ក្រុមគ្រួសារទាំងអស់គ្នាមានសុភមង្គលទាំងអស់គ្នាលោកពូ។

ខ៖បាទ! បាទ! អរគុណ!